វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

# ឯកសារស្រាវជ្រាវ

## គណៈកម្មការទី១ នៃរដ្ឋសភា

# សិទ្ធិជនអន្តោប្រវេសន៍ សិទ្ធិពលករ និង ការបណ្តេញចេញដោយបង្ខំ

ខែមិថុនា ឆ្នាំ២០១៧


អ្នកស្រាវជ្រាវ៖ **លោកស្រី គុប ដាវី**
ចូលរួមដោយ៖ **លោក សូ សុវណ្ណារិទ្ធិ**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់ សភា កម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបសសមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

### បទពិសោធន៍ ប្រទេសសិង្ហបូរី អូស្ត្រាលី និងកាណាដា អាចផ្តល់ជាមេរៀនដ៏ល្អ សម្រាប់ប្រទេសកម្ពុជា

*ប្រទេសសិង្ហបុរី ជាប្រទេសតូចមួយដែលមានប្រជាជន៥,៦លាននាក់ បានបង្កើតក្របខ័ណ្ឌគតិយុត្តិ និងក្របខ័ណ្ឌអន្តោប្រវេសន៍សម្រាប់ទទួលបានជោគជ័យ ក្នុងការទទួលយកពលករអន្តោប្រវេសន៍ ស្មើនឹង៥៤,៤ភាគរយ នៃចំនួនប្រជាជនសរុបរបស់ប្រទេសនេះដើម្បី គាំទ្រដល់គោលដៅជាតិរយៈពេលវែងសម្រាប់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព។*

*បទពិសោធន៍នៅក្នុងប្រព័ន្ធបទប្បញ្ញត្តិអន្តោរប្រវេសន៍ ដែលបង្កើតឲ្យមានការផ្គត់ផ្គង់ និងតម្រូវការ (supply-driven and demand-driven immigrant regulatory systems) គឺជាមេរៀនដ៏មានតម្លៃសម្រាប់ប្រទេសកម្ពុជា។ឧទាហរណ៍ ប្រទេសអូស្ត្រាលីទទួលជនទេសន្តរប្រវេសន៍អន្តរជាតិ ចំនួន៨,១ លាននាក់ ប្រមាណជា ២៧,៤ភាគរយ នៃចំនួនប្រជាជនសរុបចំនួន ២៤លាននាក់ របស់ប្រទេសនេះ។ ប្រទេស អូស្ត្រាលីទទួលបានចំណាត់ថ្នាក់ទី៨ ក្នុងចំណោមប្រទេសចំនួន៣៨ ក្នុងការអនុវត្តន៍ដ៏ល្អបំផុតលើ សន្ទស្សន៍គោលនយោបាយសមាហរណកម្ម ទេសន្តរប្រវេសន៍។*

*ប្រទេសកាណាដា ជាមួយនឹងគោលនយោបាយអន្តោប្រវេសន៍បើកចំហរ សម្រាប់លប់បំបាត់នូវកង្វះខាតជំនាញដើម្បីគាំទ្រដល់កំណើននិងការអភិវឌ្ឍជាតិបានទទួលជនទេសន្តរប្រវេសន៍អន្តរជាតិ ចំនួន ៧,៨លាននាក់ ឬប្រមាណ២២ភាគរយនៃចំនួនប្រជាជនសរុបចំនួន៣៥,៩លាននាក់។ ដូចប្រទេសអូស្ត្រាលីដែរជនអន្តោប្រវេសន៍គឺស្វាគមន៍ឲ្យរស់នៅនិងធ្វើការ ជាអចិន្ត្រៃយ៍ នៅក្នុងប្រទេសកាណាដាដើម្បីបំពេញ នូវចំនុចខ្វះខាតនៃជំនាញដែលបានជួបប្រទះដោយ វិស័យជាក់លាក់ណាមួយ។ ទាក់ទងនឹងការអនុវត្តន៍ដ៏ល្អបំផុតលើសន្ទស្សន៍គោលនយោបាយសមាហរណកម្មទេសន្តរប្រវេសន៍ ប្រទេសកាណាដាទទួលបានចំណាត់ថ្នាក់ទី៦។*

# សិទ្ធិជនអន្តោរប្រវេសន៍ សិទ្ធិពលករ និងការបណ្តេញចេញដោយបង្ខំ

## ១. សេចក្តីផ្តើម

ឯកសារនេះលើកយកនូវបញ្ហាសំខាន់មួយចំនួនដែលទាក់ទងនឹងសិទ្ធមនុស្សក្នុងបញ្ហាទេសន្តរប្រវេសន៍ និងការបណ្តេញចេញដោយបង្ខំ ដោយផ្តោតសំខាន់លើប្រទេសចំនួនប្រាំ (ប្រទេស អូស្ត្រាលី កាណាដា ស្វីស សិង្ហបុរី និងកម្ពុជា)។ ឯកសារនេះធ្វើឡើងដើម្បីឆ្លើយតបតាមសំណើររបស់គណៈកម្មការទី១ ទទួលបន្ទុកសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា នៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា។ ឯកសារនេះផ្តល់ជូននូវសារតាព័ត៌មានរបស់ប្រទេស ដែលបានធ្វើការជ្រើសរើសសម្រាប់គណៈកម្មការទី១ ក្នុងការរៀបចំដំណើរ ទស្សនៈកិច្ចសិក្សា ដើម្បីពិនិត្យស្ថានភាពដែលពាក់ព័ន្ធនឹងក្រប ខ័ណ្ឌគតិយុត្តិ និងគោលនយោបាយដោះស្រាយលើបញ្ហាសិទ្ធិជនអន្តោរប្រវេសន៍ សិទ្ធិពលករ និងការបណ្តេញចេញដោយបង្ខំ។

«ការធ្វើអន្តោរប្រវេសន៍» ទាក់ទងនឹងប្រជាជនដែលមករស់នៅក្នុងប្រទេសផ្សេងមួយទៀត។[1] ការធ្វើអន្តោរប្រវេសន៍ គឺជាការព្រួយបារម្ភផ្នែកនយោបាយជាសកលមួយ ដែលជាចំណែកនៃបញ្ហាសិទ្ធិមនុស្ស សិទ្ធិពលករ និងការការពារ។ ការធ្វើអន្តោរប្រវេសន៍ គឺភ្ជាប់ទាក់ទងជាមួយជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោណ និងអ្នកចល័តទីតាំងចេញពីលំនៅដ្ឋាន តាមរយៈការជួញដូរមនុស្ស ការរត់ពន្ធគ្រឿងញៀន ភេរវកម្ម និងសកម្មភាពមិនស្របច្បាប់ផ្សេងៗ ទៀត។

បញ្ហាជាច្រើនដូចគ្នាត្រូវបានលើកឡើងជាញឹកញាប់សម្រាប់ការធ្វើអន្តោប្រវេសន៍អន្តរជាតិ។ ការរំលោភបំពាន និងការកេងប្រវ័ញ្ចន៍លើទេសន្តប្រវេសជនអន្តរជាតិ និង/ឬពលករអន្តោរប្រវេសន៍កើតឡើងនៅបណ្តាប្រទេសដែលជាម្ចាស់ផ្ទះ ហើយតម្រូវឲ្យដោះស្រាយ ព្រោះ

ជាធាតុសំខាន់មួយនៃសិទ្ធិមនុស្សសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ បញ្ហាជាសកលទាំងនេះ មានផលប៉ះពាល់ខ្លាំងដល់សង្គម

សេដ្ឋកិច្ច និងនយោបាយ ព្រមទាំងមានផលវិបាកនៅក្នុងប្រទេសទទួលជនអន្តោប្រវេសន៍ (host countries) ក៏ដូចជាប្រជាជនដែលបានធ្វើទេសន្តរប្រវេសន៍ផងដែរ។ ក្នុងករណីមួយចំនួន ការបណ្តេញចេញពលករទេសន្តរប្រវេសន៍មិនស្របច្បាប់ដោយបង្ខំ បានក្លាយជាបញ្ហារសើបខាងផ្នែកនយោបាយ និងការទូត។ [2]

អស្ថេរភាពនយោបាយ និងជម្លោះប្រដាប់អាវុធ ឬក៏ការបង្ក្រាបគឺជាកត្តាសំខាន់ដែលបង្ខំឲ្យប្រជាជនក្លាយជាជនភៀសខ្លួន និងអ្នកសុំសិទ្ធិជ្រកកោណ ឬទទួលរងនូវការចល័តទីតាំងចេញពីលំនៅដ្ឋានរបស់ពួកគេ។[3] ការធ្វើអន្តោប្រវេសន៍ ក៏មាននិន្នាការនាំឲ្យមានអតុល្យភាពនៃបញ្ហាសង្គម និងសេដ្ឋកិច្ច រវាងប្រទេសបញ្ជូន និងប្រទេសទទួលជនអន្តោប្រវេសន៍ ជាពិសេសនៅពេលដែលជនអន្តោប្រវេសន៍ស្វែងរកការអប់រំ និងការងារដែលល្អប្រសើរជាងមុននៅក្នុងប្រទេសទទួលជនអន្តោប្រវេសន៍។[4]
លទ្ធផលនៃឯកសារនេះ គឺបានមកពីការពិនិត្យលើទិន្ន័យ និងឯកសារដែលមានស្រាប់ពីប្រភពបណ្ណាល័យ និងបណ្តាញអ៊ីធឺណែត ហើយនឹងដោះស្រាយលើសំនួរដូចខាងក្រោមនេះ៖

១.តើប្រទេសគោលដៅដែលបានជ្រើសរើស ធ្វើការដោះស្រាយលើបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់យ៉ាងដូចម្តេចខ្លះ?

២.តើមានគោលនយោបាយអ្វីខ្លះដែលបានអនុវត្តដោយប្រទេសដែលបានជ្រើសរើសក្នុងការការពារសិទ្ធិពលករ?

៣.តើមានការអនុវត្តន៍ល្អៗបំផុតអ្វីខ្លះ លើការដោះស្រាយបញ្ហាបណ្តេញចេញដោយបង្ខំ និងការចល័តទីតាំងពីលំនៅដ្ឋាន?

## ២. និន្នាការបច្ចុប្បន្នក្នុងការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ

ប្រទេសដែលបានលើកមកសិក្សានេះ បានផ្តល់នូវបទពិសោធន៍លើការកើនឡើងរបស់ប្រទេសដែលទទួលបានទេសន្តរប្រវេសន៍ជនអន្តរជាតិ (international migrants) ដែលរួមបញ្ចូលទាំងជនអន្តោប្រវេសន៍ នៅក្នុងអំឡុងពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ (ក្រាហ្វិក១)។[5] ដូចបណ្តាប្រទេសដ៏ទៃទៀតដែរ ប្រទេសកម្ពុជាដែលមានប្រជាជនចំនួន១៥,៥លាននាក់ ក្នុងឆ្នាំ២០១៥ បានជួបប្រទះនូវការកើនឡើងនៃចំនួនប្រជាជនចុះឈ្មោះជាទេសន្តរប្រវេសជនអន្តរជាតិ ដែលចំនួននេះមានការកើនឡើងពី ៧៣.២០០នាក់ ក្នុងឆ្នាំ ១៩៩០ ទៅ១០២.៧៣៣នាក់ក្នុងឆ្នាំ ២០១៥ (ក្រាហ្វិក១)។ [5]

**ក្រាហ្វិក១៖ និន្នាការរក្សាទុក(ចំនួន) ទេសន្តរប្រវេសជនអន្តរជាតិ តាមប្រទេស ១៩៧០-២០១៥**[5]




| | 1990 | 1995 | 2000 | 2005 | 2010 | 2015 |
|---|---|---|---|---|---|---|
| Cambodia | 73 20 | 84 74 | 96 29 | 98 44 | 100 5 | 102 7 |
| Switzerland | 1 392 | 1 478 | 1 570 | 1 805 | 2 075 | 2 438 |
| Singapore | 727 2 | 991 4 | 1 351 | 1 710 | 2 164 | 2 543 |
| Canada | 4 333 | 4 864 | 5 511 | 6 078 | 7 011 | 7 835 |
| Australia | 4 730 | 5 022 | 5 360 | 6 023 | 7 125 | 8 100 |

**ក្រាហ្វិក២៖ ចំនួនទេសន្តរប្រវេសជនអន្តរជាតិជាភាគរយនៃចំនួនប្រជាជនសរុបតាមប្រទេស ១៩៩០-២០១៥** [5]




យោងលើកំណត់ត្រាជាផ្លូវការរបស់អង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ ២០១៥ ចំនួនជនអន្តោរប្រវេសន៍នៅក្នុងប្រទេសកម្ពុជាមានស្មើរតែ២៥ដងតិចជាង កំណត់ត្រាប្រទេសសិង្ហបុរីដែលមានចំនួនប្រជាជនត្រឹមតែ ៥,៦លាននាក់ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ការមានជនអន្តោរប្រវេសន៍បានក្លាយជាបញ្ហានយោបាយ និងការទូត។ [2,6] រាជរដ្ឋាភិបាលកម្ពុជាយល់ពីតម្រូវការសម្រាប់ការបង្កើត និងពង្រឹងយន្តការច្បាប់ និងស្ថាប័នរបស់ខ្លួន ដើម្បីគ្រប់គ្រងបញ្ហាជាសកលនេះ។ បទពិសោធន៍ទាំងឡាយដែលបានប្រមូលមកពីការអនុវត្តន៍ល្អបំផុតក្នុងការគ្រប់គ្រងការធ្វើអន្តោប្រវេសន៍ ដើម្បបង្កើតនូវសន្តិភាព និងស្ថេរភាពនយោបាយសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព និងការរីកលូតលាស់នៅក្នុងប្រទេស និងតំបន់គឺមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា។

ប្រទេសពីរ អូស្រ្តាលី និងកាណាដា គឺស្ថិតនៅក្នុងចំនោមប្រទេសកំពូលទាំងដប់ទាក់ទងនឹងការធ្វើអន្តោប្រវេសន៍សុទ្ធនៅក្នុងអំឡុងឆ្នាំ២០១០ដល់២០១៥[5]៖ ប្រទេសទាំងពីរនេះទទួលបានជនអន្តោប្រវេសន៍អន្តរជាតិច្រើនជាងគេក្នុងចំណោមប្រទេសទាំងប្រាំដែលបានលើកមកសិក្សា (ក្រាហ្វិក១)។ នៅក្នុងឆ្នាំ ២០១៥ ប្រទេសសិង្ហបុរី ជាប្រទេសតូចមួយនៅក្នុងអាស៊ានមានចំនួនប្រជាជន ៥,៦លាននាក់ អាចទទួលទេសន្តរប្រវេសន៍អន្តរជាតិរហូតដល់ទៅ ២,៥លាននាក់ គឺស្មើរនឹង ៥៤,៤ភាគរយ នៃចំនួនប្រជាជនសរុបរបស់ខ្លួន។ ក្នុងចំណោមប្រទេសដែលបានលើកមកសិក្សានេះ ប្រទេសសិង្ហបុរី មានចំណែកទេសន្តរប្រវេសជនអន្តរជាតិខ្ពស់ជាងគេយោងទៅតាមចំនួនប្រជាជនសរុបរបស់ប្រទេស (ក្រាហ្វិក២)។ គោលនយោបាយទេសន្តរប្រវេសន៍

បើកចំហរសម្រាប់ពលករដែលមានជំនាញមកពីប្រទេសចិន ឥណ្ឌា និងម៉ាឡេស៊ី បានគាំទ្រដល់ការកើនឡើងនៃការនាំចេញផលិតកម្មដែលប្រើកម្លាំងពលកម្ម (labor-intensive export manufacturing) នៅក្នុងទសវត្ស៍១៩៦០ និង១៩៨០ ហើយចាប់ពីទសវត្ស៍១៩៩០ ឧស្សាហកម្មប្រពលដើមទុន និងឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យាច្រើន(capital-and technology-intensive industries) ហើយសេវាកម្មដែលមានគុណភាពខ្ពស់ បានជួយដល់ប្រទេសសិង្ហបុរីឲ្យក្លាយទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងចំណេះដឹង និងដើម្បីសម្រេចឲ្យបាននូវគោលដៅបច្ចុប្បន្នរបស់ខ្លួនក្នុងតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម (regionalization and globalization)។ [7, p. 636] នៅក្នុងបរិបទនៃកំណើនសេដ្ឋកិច្ចបច្ចុប្បន្ន ការងារថ្នាក់កណ្តាលនៅប្រទេសសិង្ហបុរី មាននិន្នាការបម្រុងទុកសម្រាប់ជនជាតិសិង្ហបុរី ខណៈពេលដែលបច្ចេកវិទ្យាទំនើប និងការច្នៃប្រឌិតខ្ពស់ចុងក្រោយ បានជម្រុញឲ្យក្រុមដែលមានទេពកោសល្យក្នុងមូលដ្ឋាន តាមរយៈការទាក់ទាញអ្នកជំនាញបរទេសដែលអាចជួយប្រទេសសិង្ហបុរីឲ្យខិតទៅជិតខ្សែចង្វាក់ឧស្សាហកម្មសំខាន់ៗដូចជា អេឡិចត្រូនិចវិទ្យា សារធាតុគីមី វិស្វកម្ម មុខវិជ្ជាសិក្សាពីជីវសាស្ត្រ ការអប់រំ ថែទាំសុខភាព ទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងការដឹកជញ្ជូន។[7]

ក្រាហ្វិក៣ ក៏សង្ខេបផងដែរនូវយុទ្ធសាស្ត្រជាក់លាក់ដែលបានប្រើដោយបណ្តាប្រទេសដ៏ទៃទៀត ដើម្បីទាក់ទាញទេសន្តរប្រវេសជនដែលមានជំនាញ ដើម្បីលប់បំបាត់កង្វះខាតជំនាញនៅក្នុងវិស័យសេដ្ឋកិច្ចរបស់ពួកគេ។[8, 9, 10] ប្រទេសអូស្ត្រាលី និងកាណាដា ទទួលបានជោគជ័យក្នុងការអនុវត្តគោលនយោបាយអន្តោប្រវេសន៍បើកចំហរ ដើម្បីបំពេញចន្លោះខ្វះខាតនៃជំនាញ ជាពិសេសវិស័យសេដ្ឋកិច្ច និងសេវាសង្គមជាក់លាក់ ដូចជាសុខាភិបាល និងការអប់រំ។ ប្រទេសទាំងពីរបានសម្រេចការងារនេះ តាមរយៈការកំណត់អត្តសញ្ញាណនៃចន្លោះខ្វះខាតនៃជំនាញ និងសារៈប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការធ្វើអន្តោប្រវេសន៍តាមអ៊ីនធឺណែត (online immigration management system)។

**ក្រាហ្វិក៣៖ ការបំពេញចន្លោះខ្វះខាតនៃជំនាញក្នុងប្រទេសដែលទទួលបានជនអន្តោប្រវេសន៍តាមរយៈទេសន្តរប្រវេសន៍ជនអន្តរជាតិ**




សម្គាល់៖
ការធ្វើផែនការរយៈពេលវែងគឺជាគន្លឹះសម្រាប់ការស្វាគមន៍ទេសន្តរប្រវេសន៍ជន ឬជនអន្តោប្រវេសន៍អន្តរជាតិ តាមរយៈគោលនយោបាយប្រង្កើតឲ្យមានការផ្គត់ផ្គង់ និងតម្រូវការ និងប្រព័ន្ធ។

នៅក្នុងប្រទេសអូស្ត្រាលី ទេសន្តរប្រវេសជននិងជនអន្តោប្រវេសន៍អន្តរជាតិបានផ្តោតសំខាន់ទាំង

មុខរបរដែលមានជំនាញខ្ពស់ និងជំនាញទាប។ នៅក្នុងឆ្នាំ ២០១៤/១៥ មានអ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នប្រមាណ ៩៥ភាគរយ នៃ៤៥៧ ត្រូវបានជ្រើសរើសឲ្យធ្វើការក្នុងកន្លែងដែលមានជំនាញខ្ពស់ បានចាត់ជាក្រុម «អ្នកគ្រប់គ្រង» «អ្នកជំនាញ» ឬ «អ្នកបច្ចេកទេស និងពាណិជ្ជកម្ម» ដែលបង្ហាញពីលក្ខណៈ«ជំនាញ»នៃគម្រោងផែនការចំនួន៤៥៧។ [9]

នៅក្នុងប្រទេសកាណាដា ការងារកំពូលទាំងដប់ដែលពិបាកក្នុងការបំពេញក្នុងឆ្នាំ២០១៥ រួមមានៈ ១) ពលករដែលមានជំនាញខាងពាណិជ្ជកម្ម (skilled trades workers) ២) អ្នកបច្ចេកទេស ៣) អ្នកតំណាងផ្នែកលក់ ៤) លេខាធិការ ជំនួយការផ្ទាល់ ជំនាញរដ្ឋបាល និងបុគ្គលិកជំនួយការិយាល័យ ៥) អ្នកបើកបរ ៦) វិស្វករ ៧) អ្នកគ្រប់គ្រង/នាយកប្រតិបត្តិ ៨)ប្រតិបត្តិករផលិតកម្ម/ម៉ាស៊ីន ៩) បុគ្គលិកគណនេយ្យ និងហិរញ្ញវត្ថុ និង១០) កម្មករ។[11, p.8]

នៅក្នុងឆ្នាំ ២០១៥ មានទេសន្តរប្រវេសន៍ជនជាង៧0.000នាក់មកពីអនុតំបន់សាហារ៉ាទ្វីបអាហ្វ្រិក (sub-Saharan Africa) បានមករស់នៅក្នុងប្រទេសស្វីស។[12] សិទ្ធិក្នុងការធ្វើទេសន្តរប្រវេសន៍ត្រូវបានផ្តល់ដោយប្រទេសស្វីសដល់ទេសន្តរប្រវេសជនអាហ្វ្រិកដោយផ្អែកលើតម្រូវការដើម្បីគេចពីសង្គ្រាម ភាពក្រីក្រ ឬអស្ថេរភាពនយោបាយដើម្បីស្វែងរកជីវិតប្រសើរជាងមុននៅក្នុងតំបន់អឺរ៉ុប។ ប្រទេសស្វីស គឺជាប្រទេសដែលមានប្រជាជនតិចជាងគេក្នុងចំណោមប្រទេសនៅតំបន់អឺរ៉ុប ហើយកំពុងតែទាក់ទាញទេសន្តរប្រវេសន៍ជនដែលមានជំនាញខ្ពស់ ដែលបានបញ្ចប់ការសិក្សាថ្នាក់ខ្ពស់នៅក្នុងប្រទេសកំណើតរបស់ខ្លួននៅទូទាំងប្រទេស។ ឱកាសការងារផ្សេងៗគ្នាសម្រាប់ទេសន្តរប្រវេសជនត្រូវបានរកឃើញក្នុងវិស័យពាណិជ្ជកម្ម ហិរញ្ញវត្ថុ ការទូត សុខាភិបាល និងឱសថស្ថាន។ លោកស្រីសារ ( Sarr) [13] ក៏បានកំណត់ផងដែរនូវការធ្វើទេសន្តរប្រវេសន៍របស់អ្នកដែលមានជំនាញខ្ពស់មកពីទិសខាងជើង( ឧ.ទ.បណ្តាប្រទេសដែលមានការអភិវឌ្ឍល្អនៅអឺរ៉ុប) ទៅកាន់ទិសខាងត្បូង(ឧ.ទ. បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចនៅទ្វីបអាហ្វ្រិក។ ភាពចម្រូងចម្រាសដ៏ច្រើនសន្ធឹកសន្ធាប់ ក៏បានលើកយកមកពិភាក្សាផងដែរដោយលោកស្មិត (Schmid) នៅក្នុងឆ្នាំ២០១៦ ដោយផ្តោតលើ «ការបាត់បង់អ្នកជំនាញដែលមានការអប់រំខ្ពស់» (brain-drain of well-educated professionals) ជាការតំណាងឲ្យការបាត់បង់កម្លាំងពលកម្មនៅក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួច។[14]

សរុបមក តាមរយៈនិយមន័យការធ្វើទេសន្តរប្រវេសន៍ និងអន្តោប្រវេសន៍អន្តរជាតិ គឺពិតជាមិនដូចគ្នាទេ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើទេសន្តរប្រវេសន៍បណ្តោះអាសន្ន ត្រូវបានមើលឃើញថាជាផ្នែកអន្តរកាលក្លាយជាស្ថានភាពអន្តោប្រវេសន៍ បង្កឲ្យមានភាពងាយស្រួលដល់ទេសន្តរប្រវេសជនតាំងទីលំនៅ

ក្នុងប្រទេសទទួលជនអន្តោប្រវេសន៍។ ទេសន្តរប្រវេសជន និងអន្តោប្រវេសន៍អន្តរជាតិ បានដើរតួរយ៉ាងសំខាន់ក្នុងការពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងការធ្វើសមាហរណកម្ម ដែលជាប្រយោជន៍ដល់ប្រទេសដែលបញ្ជូន និងប្រទេសទទួល។ ហេតុផលទាំងនេះហើយ បានជាការធ្វើទេសន្តរប្រវេសន៍អន្តរជាតិត្រូវបានដាក់បញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាពសម្រាប់ឆ្នាំ២០៣០។[15]

## ៣. ការបណ្តេញចេញដោយបង្ខំ/ការចល័តពីលំនៅដ្ឋាន

ការបណ្តេញចេញដោយបង្ខំ ត្រូវបានកំណត់ថា *«ជាការដេកចេញបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ប្រឆាំងនឹងឆន្ទៈបុគ្គល គ្រួសារ និង/ឬសហគមន៍ពីផ្ទះ និង/ឬដីធ្លីដែលពួកគេកាន់កាប់ ដោយគ្មានការផ្តល់ និងការទទួលបានទម្រង់បែបបទច្បាប់សមស្រប ឬក៏ការការពារផ្សេងៗ»* ។[16] ប្រជាជនដែលរងផលប៉ះពាល់រួមមាន ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោណ ជនមាតុភូមិនិវត្តន៍ អ្នកគ្មានសញ្ជាតិ និងក្រុម ចល័តទីនៅក្នុងប្រទេសមួយចំនួន ហើយត្រូវបានសំដៅជារួមជា «ការព្រួយបារម្ភរបស់បុគ្គល» (persons of concern)។ បើយើងអង្គការសហប្រជាជាតិសិទ្ធមនុស្ស (UNHCR) [17] នៅទូទាំងពិភពលោក ការចល័តលំនៅដ្ឋានដោយបង្ខំបានកើនឡើងរហូតដល់៦៥,៣លាននាក់ នៅក្នុងឆ្នាំ២០១៥ ពី ៥៩,៥លាននាក់ ក្នុងឆ្នាំមុន។ ប្រជាជនទាំងនេះ គឺចល័តទីលំនៅដោយបង្ខំនៅទូទាំងពិភពលោកដោយសារការបៀតបៀន សង្គ្រាម អំពើហឹង្សាទូទៅ ឬក៏ការរំលោភបំពានសិទ្ធិមនុស្ស។

មូលហេតុនៃការបណ្តេញចេញ/ការចល័តទីលំនៅដោយបង្ខំត្រូវក៏បានកត់សម្គាល់ដោយកម្មវិធីអង្គការសហប្រជាជាតិដំណោះស្រាយបញ្ហាប្រជាជន UN-HABITAT [16, p.4] ផងដែរ ដែលអាចសង្ខេបបានដូចខាងក្រោមនេះ៖

១. គម្រោងអភិវឌ្ឍន៍ទីក្រុង និងជនបទ ដូចជាទំនប់ទឹក ផ្លូវថ្នល់ ការរុករករ៉ែ ការជីករុករករ៉ែ និងតំបន់ឧស្សាហកម្មផ្សេងទៀត (extractive and other industrial zoning)

២. អចលនទ្រព្យ និងសកម្មភាពអាជីវកម្មឯកជន រួមទាំង អចលទ្រព្យ «ឡោមព័ទ្ធយ៉ាងកុះករ» (ឬការបណ្តេញចេញដោយបង្ខំ)

៣. ជម្លោះនយោបាយ និងជម្លោះជនជាតិដើមភាគតិច ដើម្បីលប់បំបាត់ជនជាតិដើមតិច និងការផ្ទេរប្រជាជន

៤. ជម្លោះប្រដាប់អាវុធជាតិ និងអន្តរជាតិ និងការកំណត់គោលដៅលំនៅដ្ឋានរបស់ប្រជាពលរដ្ឋស៊ីវិល រួមទាំងការដាក់ទណ្ឌកម្មរួម និងវិធានការ«ទប់ស្កាត់ភេរវកម្ម» (counter-terrorism)។

ការបណ្តេញចេញដោយបង្ខំតែងតែមានភាពចម្រូងចម្រាស់ក្នុងបរិបទសិទ្ធិមនុស្សនៅពេលដែលការបានកើតមានឡើងនៅក្នុងបណ្តាប្រទេស ត្រូវបានវិភាគនៅក្នុងការសិក្សានេះសម្រាប់គោលបំណងអភិវឌ្ឍន៍ណាមួយ។ ការព្រួយបារម្ភពីបញ្ហាសិទ្ធិមនុស្សអន្តរជាតិ គឺផ្តោតលើការបាត់បង់សង្គម និងសេដ្ឋកិច្ច នៃការបណ្តេញចេញដោយបង្ខំ ដែលជាមូលហេតុបណ្តាលមកពីការធ្វើផែនការពីថ្នាក់កំពូលហូតដល់ថ្នាក់ទាប (top-down planning) ដែលមិនមានការចរចារ និងពិគ្រោះយោបល់គ្រប់គ្រាន់ជាមួយនឹងសហគមន៍ដែលរងផលប៉ះពាល់[18]។ នៅប្រទេសកាណាដា ការបណ្តេញចេញដោយបង្ខំជាច្រើនបានកើតឡើងនៅក្នុងវិស័យឯកជន ដែលបានលទ្ធផលពីការដាក់ពាក្យស្នើសុំ បណ្តេញចេញពីសំណាក់ម្ចាស់ដី ដែលជាមូលហេតុជំទាស់នឹងអ្នកជួលដី។ សកម្មភាពបែបនេះ គំរាមកំហែងប្រឆាំងនឹងសិទ្ធិក្នុងការទទួលបានលំនៅដ្ឋានសមរម្យ។ ទោះបីជាច្បាប់ គោលនយោបាយ និងនីតិវិធីតុលាការបានកំណត់យ៉ាងច្បាស់លាស់យ៉ាងណាក៏ដោយ ការព្រួយបារម្ភកើតឡើងចំពោះរំលោភបំពានច្បាប់អន្តរជាតិ នៅពេលដែលគោនយោបាយទាំងនេះ និងការអនុវត្តច្បាប់ការការពារអ្នកជួល (Tenant Protection Act) បានអនុម័តក្នុងឆ្នាំ ១៩៩៨។[19]

បន្ថែមទៅនឹងក្របខណ្ឌគតិយុត្តិដែលមានមូលដ្ឋានល្អ ក្នុងការដោះស្រាយជាមួយនឹងការបណ្តេញចេញដោយបង្ខំ ប្រទេសអូស្ត្រាលី បានប្តេជ្ញានឹងផ្តល់សំណងដល់ប្រជាជនជនដើមអូស្ត្រាលីដែលរស់នៅតាំងពីបុរាណ ដែលត្រូវបានបណ្តេញចេញដោយបង្ខំពីស្រុកកំណើតរបស់ពួកគេ។[20] ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍របសប្រទេសក្នុងការបណ្តេញចេញដោយបង្ខំក្នុងប្រទេស មិនមែនជាកម្មវត្ថុសំខាន់ក្នុងការសិក្សានេះទេ។ បទពិសោធន៍នេះជាវិធានការណ៍អន្តរជាតិដែលត្រូវបានអនុម័តដើម្បីដោះស្រាយទម្រង់ផ្សេងៗនៃការបណ្តេញចេញដោយបង្ខំ ដែលទាក់ទងនឹងជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោណ និងជនអន្តោប្រវេសន៍អន្តរជាតិ។

មានប្រជាជនប្រភេទខុសគ្នាជាច្រើន ដែលអាចចាត់ចូលក្នុងប្រភេទដែលពាក់ព័ន្ធមានបង្ហាញនៅក្នុងតារាងទី១។ ប្រទេសសិង្ហបុរី មិនមែនជាទីកន្លែងដែលមនុស្សចល័តទីលំនៅដោយបង្ខំត្រូវតាំងទីលំនៅនោះទេ។ ផ្ទុយទៅវិញ នៅក្នុងឆ្នាំ២០១៥ ប្រទេសកាណាដា (២២.៩០០) និងអូស្ត្រាលី (៩.៣០០) បានទទួលជនភៀសខ្លួនចំនួន២៤ភាគរយ បានកំណត់អត្តសញ្ញាណសម្រាប់ការតាំងលំនៅថ្មី ដោយអង្គការសហប្រជាជាតិសិទ្ធិមនុស្ស។ [17, p.26] ប្រទេសទាំងនេះ បានផ្តល់ការការពារផ្នែកច្បាប់ និងរូបរាងកាយដល់ជនភៀសខ្លួន រួមទាំងការទទួលបាននូវសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ស្រដៀងគ្នាទៅនឹងជនជាតិរបស់ខ្លួន។

នៅប្រទេសកាណាដា មានជនភៀសខ្លួនជាង១០.០០០នាក់ បានតាំងទីលំនៅថ្មីក្នុងមួយឆ្នាំៗ ផ្នែកដ៏សំខាន់មួយក្នុងការស្រូបចូលជនភៀសខ្លួនប្រចាំឆ្នាំពី ២០០.០០០នាក់ ដល់ ៣៥០.០០០នាក់ តាមរយៈការបង្កើតកម្មវិធីតាំងទីលំនៅថ្មី និងសិទ្ធិជ្រកកោណ។[10] ទោះបីជា (៣២ភាគរយ) នៃការស្ទង់មតិនិយោជកនៅប្រទេសកាណាដាបានរាយការណ៍ថា ការវិបាកក្នុងការជ្រើសរើសពលករដែលពួកគេចង់បានដោយសារតែមានការកង្វះខាតជំនាញ។

តារាង១៖ ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោណ អ្នកចល័តទីនៅក្នុងប្រទេស ជនមាតុភូមិនិវត្តន៍(ជនភៀសខ្លួន និងអ្នកចល័តទីនៅក្នុងប្រទេស) អ្នកគ្មានសញ្ជាតិ និងការព្រួយបារម្ភផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិសិទ្ធិមនុស្ស (UNHCR) តាមប្រទេស/ទឹកដី នៃសិទ្ធិជ្រកកោណ ក្នុងឆ្នាំ២០១៥ [17, pp.57-59]

| | កាណាដា | ស្វីស | អូស្ត្រាលី | កម្ពុជា | សិង្ហបុរី | ពិភពលោក* |
|---|---|---|---|---|---|---|
| ចំនួនជនភៀសខ្លួនសរុប និងប្រជាជនស្ថិតក្នុងស្ថានភាពដូចជនភៀសខ្លួន | ១៣៥.៨៨៨ | ៧៣.៣៣៦ | ៣៦.៩១៧ | ៧៦ | | ១៦.១២១.៤២៧ |
| អ្នកដែលបានជួយដោយអង្គការសហប្រជាជាតិសិទ្ធិមនុស្ស | - | - | - | ៧១ | | ១២.២៨២.៧៩២ |
| អ្នកស្វែងរកសិទ្ធិជ្រកកោណ (ករណីមិនទាន់ដោះស្រាយ) | ១៩.៦៤២ | ៣២.៧០១ | ២០.៦៧៧ | ២៧ | | ៣.២១៩.៩៤១ |
| មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួន | - | - | - | ១ | | ២០១.៤១៥ |
| និបេតិកជន(អ្នកគ្មានសិទ្ធិក្លាយជាប្រជាពលរដ្ឋ)ដែលស្ថិតក្រោមអណត្តិរបស់អង្គការសហប្រជាជាតិសិទ្ធិមនុស្ស | - | ៦៩ | - | - | | ៣.៦៨៧.៧២៩ |
| អ្នកផ្សេងទៀតដែលស្ថិតក្នុងការព្រួយបារម្ភរបស់អង្គការសហប្រជាជាតិសិទ្ធិមនុស្ស | - | - | - | ១៩៧ | ១ | ៨៧០.៧៤០ |
| ចំនួនប្រជាជននៃការព្រួយបារម្ភសរុប | ១៥៥.៥៣ | ១០៦.១០៦ | ៥៧.៥៩៤ | ៣០ | ១ | ៣៦.៣៨៤.០៤៤ |

សម្គាល់៖ មិនមានកំណត់ត្រានៃអ្នកចល័តទីនៅក្នុងប្រទេស និងអ្នកចល័តទីនៅក្នុងប្រទេសត្រលប់មកវិញ កត់ត្រានៅក្នុងរបាយការណ៍ ( ឧបសម្ព័ន្ធ១)

នៅក្នុងឆ្នាំ២០០៩ អង្គការសហប្រជាជាតិបានអំពាវនាវឲ្យរដ្ឋាភិបាលបញ្ឈប់ការបណ្ដេញចេញ/ចល័តប្រជាពលរដ្ឋពីលំនៅដ្ឋានដោយបង្ខំ [21] ទោះបីជា ករណីនេះត្រូវបានគេទទួលស្គាល់ថាមិនមែនគ្រប់ករណីបណ្ដេញចេញទាំងអស់ ស្ថិតនៅក្រោមការហាមខាត់របស់ច្បាប់សិទ្ធិមនុស្សក៏ដោយ។[19, p.5] សារៈសំខាន់នៃសមភាព ការធ្វើសាមាហរណកម្មទេសន្តរប្រវេសជនអន្តរជាតិទៅក្នុងប្រទេសដែលទទួលបាន បានក្លាយជារបៀបវារៈចម្បងរបស់អង្គការសហប្រជាជាតិ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព ២០៣០។[15]

## ៤. សិទ្ធិពលករអន្តោប្រវេសន៍

ការគោរពសិទ្ធិពលករអន្តោប្រវេសន៍ គឺត្រូវបានគាំទ្រក្នុងការដាក់បញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាពទី៨.៨ ដែលជម្រុញឲ្យប្រទេសទាំងអស់៖

> «ការពារសិទ្ធិកម្មករ និងលើកកម្ពស់សុវត្ថិភាព និងរក្សាសុវត្ថិភាពបរិយាកាសការងាររបស់ពលករទាំងអស់ រួមទាំង ពលករទេសន្តរប្រវេសន៍ ជាពិសេសពលករទេសន្តរប្រវេសន៍ជាស្ត្រី និងអ្នកដែលធ្វើការងារបណ្ដោះអាសន្ន»។[22]

ប្រទេសសិង្ហបុរី បានបង្កើតក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងជនអន្តោប្រវេសន៍ខុសច្បាប់ ការពារសិទ្ធិពលករអន្តោប្រវេសន៍តាមរយៈបទប្បញ្ញត្តិនៃការផ្ដល់លិខិតអនុញ្ញាតការងារដល់កម្មករផ្សេងៗគ្នា តាមជំនាញខុសៗគ្នា ហើយប្រាក់កម្រៃ និងអត្ថប្រយោជន៍សុខុមាលភាព សម្រាប់ពលករ/និយោជិកជាតិ និងអន្តរជាតិ(តារាងទី៣)។

កម្រិតនៃភាពជោគជ័យដែលប្រទេសអូស្ត្រាលី និងកាណាដា ទទួលបានក្នុងការគាំទ្រសិទ្ធិពលករអន្តោប្រវេសន៍ ត្រូវបានបង្ហាញដោយលទ្ធផលនៃការសមាហរណកម្មគោលនយោបាយទេសន្តោប្រវេសន៍របស់ពួកគេ បានបង្ហាញនៅក្នុងតារាងទី២។ ការចាត់ចំណាត់ថ្នាក់របស់ប្រទេសនីមួយៗ បានមកពីពិន្ទុជាមធ្យមជាក់លាក់នៃការធ្វើសមាហរណកម្មគោនយោបាយទេសន្តោប្រវេសន៍របស់ពួកគេ ដំណើរការដោយក្រុមគោលនយោបាយទេសន្តរប្រវេសន៍ដើម្បីសន្ទស្សន៍គោលនយោបាយសមាហរណកម្មទេសន្តរប្រវេសន៍ (MIPEX) ក្នុងចំណោមប្រទេសទាំង៣៨ នៅក្នុងឆ្នាំ ២០១៤។[23] ប្រទេសកាណាដា បានកាន់កាប់សន្ទស្សន៍គោលនយោបាយសមាហរណកម្មទេសន្តរប្រវេសន៍ខ្ពស់មធ្យមមានពិន្ទុ ៦៨ ប្រៀបធៀបជាមួយប្រទេសអូស្ត្រាលី(៦៦) និងប្រទេសស្វីស (៤៦) ក្នុងការអនុវត្តន៍ល្អបំផុតទាក់ទងនឹងគោលនយោបាយ

សាមាហរណកម្មទេសន្តរប្រវេសន៍ឆ្នាំ២០១៤។[24, p.8] សម្រាប់និយមន័យលម្អិតនៃពិន្ទុសន្ទស្សន៍គោលនយោបាយសមាហរណកម្មទេសន្តរប្រវេសន៍នីមួយៗ សូមពិនិត្យមើលក្នុងឧបសម្ព័ន្ធទី២។

**តារាង២៖ សន្ទស្សន៍គោលនយោបាយសាមាហរណកម្មទេសន្តរប្រវេសន៍២០១៤ (ពិន្ទុ)[15]**

| | កាណាដា | អូស្ត្រាលី | ស្វីស | ស៊ុយអែត | តួកគី |
|---|---|---|---|---|---|
| ចំណាត់ថ្នាក់ | ទី៦ | ទី៨ | ទី២១ | ទី១ | ទី៣៨ |
| ពិន្ទុMIPEX | ៦៨ | ៦៦ | ៤៩ | ៧៨ | ២៥ |
| បំរែបំរួលទីផ្សារការងារ | ៨១ | ៥៨ | ៥៩ | ៩៨ | ១៥ |
| ការជួបជុំគ្រួសារ | ៧៩ | ៦៧ | ៤៨ | ៧៨ | ៤៩ |
| ការអប់រំ | ៦៥ | ៧៦ | ៤២ | ៧៧ | ៥ |
| សុខភាព | ៤៩ | ៦៧ | ៧០ | ៦២ | ៣២ |
| ការចូលរួមនយោបាយ | ៤៨ | ៦៤ | ៥៨ | ៧១ | ១១ |
| លំនៅដ្ឋានអចិន្ត្រៃយ៍ | ៦២ | ៥៤ | ៥១ | ៧៩ | ២៧ |
| ការទទួលបានសញ្ញាតិ | ៦៧ | ៦៩ | ៣១ | ៧៣ | ៣៤ |
| ប្រឆាំងនឹងការរើសអើង | ៩២ | ៧៤ | ៣១ | ៨៥ | ២៦ |

សម្គាល់៖ គាំទ្រ=៨០-១០០ គាំទ្របន្តិចបន្តួច=៦០-៧៩ គាំទ្រពាក់កណ្ដាល=៤១-៥៩ មិនគាំទ្របន្តិចបន្តួច= ២១-៤០ មិនគាំទ្រ = ១-២០ មិនគាំទ្រទាល់តែសោះ = 0

ដើម្បីទទួលបានជោគជ័យ ការធ្វើសមាហរណកម្មតម្រូវឲ្យមានការដោះស្រាយយ៉ាងទូលំទូលាយ និងជាប់ជាប្រចាំពីបណ្ដុំច្បាប់ សេដ្ឋកិច្ច វប្បធម៌ នយោបាយ និងទំហំពលរដ្ឋ។លក្ខណៈវិនិច្ឆ័យនៃការធ្វើសមាហរណកម្មទាំងនេះ ត្រូវបានអនុវត្តទៅតាមទេសន្តរប្រវេសជនអន្តរជាតិ និងប្រជាជនដែលត្រូវបានចល័តទីលំនៅដោយបង្ខំដូចជាជនភៀសខ្លួន ជនដែលចល័តទីលំនៅក្នុងប្រទេស ឬក៏និបេតិកជន ហើយពួកគេមានសិទ្ធិដូចគ្នាទៅនឹងជនជាតិនៅក្នុងប្រទេសទាំងនោះដែរ។ សមទ្ធិផលនៃដំណោះស្រាយ យ៉ាងទូលាយតម្រូវឲ្យមានការប្រមូលផ្ដុំនូវការប្ដេជ្ញាចិត្តជាសកលមួយ ដើម្បីដោះស្រាយលើ ឫសគល់នៃបញ្ហាចល័តទីលំនៅរួមជាមួយនឹងការពិចារណាយ៉ាងទូលំទូលាយក្នុងការជ្រើសរើស និងឱកាស។[21,p.23] បើគ្មានសុវត្ថិភាពបរិកាស រដ្ឋបាល និងផ្លូវច្បាប់ដើម្បីដំណោះស្រាយជាផ្លូវការ និងការដាក់បញ្ចូលទេសន្តរប្រវេសជនអន្តរជាតិ និងជនល័តទីលំនៅទៅក្នុងទិដ្ឋភាពទាំងអស់នៃជីវិតសង្គម និងវប្បធម៌វានឹងមិនអាចសម្រេចបាននូវគោលដៅរបស់អង្គការសហប្រជាជាតិឆ្នាំ២០៣០នោះទេ។[22]

## ៥. បទពិសោធន៍របស់ប្រទេសសិង្ហបុរី អូស្ត្រាលី និងប្រទេសកាណាដា ក្នុងការគ្រប់គ្រងជនអន្តោប្រវេសន៍ សិទ្ធិពលករ និងការបណ្តេញចេញដោយបង្ខំ គឺផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ដល់ប្រទេសកម្ពុជាក្នុងការពិចារណា

បទពិសោធន៍របស់បណ្តាប្រទេសដែលបានលើកមកសិក្សានេះ គឺគាំទ្រដល់ការជ្រើសរើសប្រទេសសិង្ហបុរី និងប្រទេសមួយទៀតក្នុងចំណោមប្រទេសកាណាដា ឬក៏ប្រទេសអូស្ត្រាលី លើសំណើរសុំទស្សនកិច្ចរបស់គណៈកម្មការទី១។

ផ្អែកលើចំណាត់ថ្នាក់ទាប និងពិន្ទុដាក់លាក់ នៃគោលនយោបាយសមាហរណកម្មទេសន្តរប្រវេសន៍ (Migration Integration Policy) (បានកត់សម្គាល់ក្នុងតារាងទី២ និងឧបសម្ព័ន្ធទី២) បទពិសោធន៍របស់ប្រទេសស្វីសអាចជាប់ពាក់ព័ន្ធតិចតួចសម្រាប់ប្រទេសកម្ពុជា។ ទាំងនេះពីព្រោះតែការរឹតបន្តឹងលើគោលនយោបាយអន្តោប្រវេសន៍បើកចំហរ ដែលគោរពទៅតាមតម្រូវការលើគ្រប់ជំនាញដែលស្ថិតនៅក្រោមសន្ធិសញ្ញាទ្វេភាគីជាមួយសហភាពអឺរ៉ុប ស្តីពីការផ្លាស់ប្តូរទីតាំងដោយសេរីរបស់ប្រជាជន។[25] ក្រៅពីប្រជាពលរដ្ឋរបស់សហភាពអឺរ៉ុប ច្បាប់ទេសន្តរប្រវេសន៍របស់ប្រទេសស្វីស ផ្តល់ការងារទាំងស្រុងដល់ពលករអន្តោប្រវេសន៍ដែលមានជំនាញខ្ពស់។ កម្មវិធីជាច្រើនបានវាយតម្លៃយ៉ាងតឹងរឹងក្នុងការធ្វើនិយ័តកម្មលើវត្តមានទេសន្តរប្រវេសជនដែលគ្មានឯកសារ និងធ្វើការនៅក្នុងប្រទេសស្វីស។ វិធានការទាំងនេះ កំណត់គោលនយោបាយផ្លាស់ប្តូរដល់ការផ្តល់សិទ្ធិដល់ពលករទេសន្តរប្រវេសន៍ដែលមានជំនាញខ្ពស់ និងជនភៀសខ្លួនដើម្បីតាំងទីលំនៅ នៅក្នុងប្រទេសស្វីស។[26]

ប្រទេសកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលសំខាន់មួយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ នៅពេលជាមួយគ្នានេះដែរ កម្ពុជាត្រូវតែកសាងធនធានមនុស្សរបស់ខ្លួនដើម្បីទាក់ទាញការវិនិយោគលើគ្រប់វិស័យអភិវឌ្ឍន៍ទាំងអស់។ បទពិសោធន៍របស់ប្រទេសសិង្ហបុរី និងប្រទេសអូស្ត្រាលី ឬប្រទេសកាណាដាមានតម្លៃខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា និងអាចចាត់ជាក្រុមយ៉ាងទូលាយទៅក្នុង៖

1) ការត្រួតពិនិត្យលើការធ្វើអន្តោប្រវេសន៍ ឬបទប្បញ្ញត្តិគោលនយោបាយ (បទប្បញ្ញត្តិ និងនីតិវិធីគ្រប់គ្រងលើការជ្រើសរើស និងទទួលយកជនបរទេស) និង
2) គោលនយោបាយអន្តោប្រវេសន៍ (ល័ក្ខខ័ណ្ឌដែលបានផ្តល់ឲ្យសម្រាប់ជនអន្តោប្រវេសន៍ដែលបានតាំងទីលំនៅជាអចិន្ត្រៃយ៍ ដូចជាការងារ និងល័ក្ខខ័ណ្ឌនៃការរស់នៅ ការផ្តល់សេវាសុខាភិបាល និងឱកាសក្នុងការទទួលបានការអប់រំ)។

## បទពិសោធន៍របស់ប្រទេសសិង្ហបុរី

នៅប្រទេសសិង្ហបុរី ក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិ សម្រាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើការងាររបស់ពលកម្មបរទេស (តារាងទី៣) បានបង្កើតឡើងដើម្បីត្រួតពិនិត្យពីទំហំ រយៈពេលនៃការស្នាក់នៅ សមាសភាពជំនាញ និងជនជាតិភាគតិច ជាតិសាសន៍ និងប្រភពនៃទីតាំងភូមិសាស្ត្រ របស់ទេសន្តរប្រវេសជនដែលប្រទេសគេបានទទួលយក។[27] ក្របខ័ណ្ឌគតិយុត្តិនេះត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាព និងតម្លាភាព ដោយការិយាល័យផ្តល់ប័ណ្ណការងារ (Work Pass Division) និងនាយកដ្ឋានគ្រប់គ្រងកម្លាំងពលកម្មបរទេស (Foreign Manpower Management Division) នៅក្នុងក្រសួងការងារ (Ministry of Manpower)។ ការិយាល័យផ្តល់ប័ណ្ណការងារ ផ្តល់នូវលទ្ធភាព ប្រសិទ្ធិភាព និងគម្រោងទទួលស្គាល់កម្លាំងពលកម្មបរទេស ដែលអាចបំពេញតម្រូវការសេដ្ឋកិច្ចរបស់ប្រទេសសិង្ហបុរី។ ការិយាល័យនេះបានជួយសម្របសម្រួល និងធ្វើនិយ័តកម្មការងាររបស់ជនជាតិបរទេស តាមរយៈការផ្តល់នូវ ប័ណ្ណការងារចំនួនបីប្រភេទ។ មុខងារសំខាន់ៗរបស់ការិយាល័យគ្រប់គ្រងកម្លាំងពលកម្មបរទេសរួមមាន៖ (១) ការគ្រប់គ្រង និងការការពារកម្លាំងពលកម្មបរទេស (២) វិជ្ជាជីវៈនៃភ្នាក់ងារឧស្សាហកម្មការងារ និង (៣) ពង្រឹងសមត្ថភាពក្នុងការអនុវត្ត។ ការិយាល័យគ្រប់គ្រងកម្លាំងពលកម្មបរទេស គឺគ្រប់គ្រងដោយនាយកដ្ឋានចំនួនបួន៖

1) នាយកដ្ឋានការងារអធិការកិច្ច ដែលព្យាយាមជួយជម្រុញប្រសិទ្ធិភាពនៃការគ្រប់គ្រងកម្លាំងពលកម្មបរទេស តាមរយៈគោលនយោបាយដែលភ្ជាប់ដៃគូរជាមួយភ្នាក់ងារអនុវត្តច្បាប់ និងសហគមន៍ពាណិជ្ជកម្ម
2) នាយកដ្ឋានគោលនយោបាយ និងបទប្បញ្ញាត្តិ ផ្តោតទៅការព្រាង និងការអនុវត្តគោលនយោបាយ សម្រាប់ការិយាល័យគ្រប់គ្រងកម្លាំងពលកម្មបរទេស
3) នាយកដ្ឋានគ្រប់គ្រងសុខុមាលភាព ផ្តោតទៅការគ្រប់គ្រង និងការការពារកម្លាំងពលកម្មបរទេស និង
4) នាយកដ្ឋានគ្រប់គ្រងសហប្រតិបត្តិការ គាំទ្រលើផ្នែកទាំងអស់នៃការិយាល័យគ្រប់គ្រង

**តារាងទី៣៖ ក្របខណ្ឌគតិយុត្តិ និងគោលនយោបាយ ឬប្រពន្ធ័អន្តោប្រវេសន៍៖ បទពិសោធន៍នៃបណ្តាប្រទេសដែលបានលើកមកសិក្សា**

| | **ការត្រួតពិនិត្យអន្តោប្រវេសឬ ក្របខណ្ឌគតិយុត្តិ** | **គោលនយោបាយអន្តោប្រវេសន៍** | |
|---|---|---|---|
| | | <u>**ប្រព័ន្ធដែលបង្កើតឲ្យមានការផ្គត់ផ្គង់**</u> | <u>**ប្រព័ន្ធដែលបង្កើតឲ្យមានតម្រូវការ**</u> |
| សិង្ហបុរី[28] | -ច្បាប់ការងាររបស់ពលករបរទេសឆ្នាំ២០១២ (Employment of Foreign Manpower Act) បង្កើតឡើងដើម្បីបង្កើនសមត្ថភាពរដ្ឋាភិបាលក្នុងការធានាឲ្យបាននូវបូរណភាពនៃក្របខ័ណ្ឌប័ណ្ណអនុញ្ញាតការងារ<br>-ច្បាប់អន្តោប្រវេសន៍ (Immigration Act) ច្បាប់របស់ភ្នាក់ងារផ្តល់ការងារ (Employment Agencies Act)<br>-ការងាររបស់ពលករបរទេស (កាតព្វកិច្ចបង់ពន្ធ(levy order))<br>-បទប្បញ្ញត្តិការងាររបស់ពលករបរទេស (ប្រាក់កម្រៃ)លិខិតបញ្ជាក់ស្តីពីការអនុញ្ញាតការងារ (ការរួមបញ្ចូលគ្នា)<br>-លិខិតបញ្ជាក់ការងាររបស់ពលករបរទេស (ធានាសុវត្ថិភាពនៅកន្លែងការងារ) | - គោលនយោបាយជាក់លាក់ជាច្រើនសំដៅទៅលើពលករបរទេសពាក់កណ្តាលជំនាញ រួមទាំងវិញ្ញាបនប័ត្រជំនាញមូលដ្ឋាន (Basic Skills Certificate) និងវិញ្ញាបនប័ត្រ ជំនាញវាយតម្លៃ (Skills Evaluation Certificate) គម្រោងចាប់ពី២៣ទៅ៥០ឆ្នាំ នៅឆ្នាំ១៩៩៨<br>- ការធ្វើតេស្តជ្រើសរើសពលករបរទេសចូលក្នុងស្រុក មានចាប់តាំងពីឆ្នាំ២០០៥ មកម្លេះ<br>- សមាគមន៍បណ្តុះបណ្តាលជំនាញកម្មករបរទេសក្នុងស្រុក (Foreign Domestic Worker Association for Skills Training) វគ្គបឋម ស្តីពីការថែទាំកម្មករបរទេសរំយចំណាស់ក្នុងស្រុក<br>- អនុម័តលើប្រទេសដើម និងវិស័យសេដ្ឋកិច្ច | -អនុម័តលើប្រទេសដើម និងវិស័យសេដ្ឋកិច្ច<br>-គម្រោងដកពន្ធលើពលករបរទេស ឆ្នាំ១៩៨០<br>-ការកំណត់ចំនួន គឺជាឧបករណ៍សម្រាប់គ្រប់គ្រងការងាររបស់ពលករបរទេសនៅក្នុងឆ្នាំ១៩៨៧<br>-ទីភ្នាក់ងារផ្តល់ការងារ (មានចំនួន១៣០០ ភ្នាក់ងារជ្រើសរើសបុគ្គលិកមានអាជ្ញាប័ណ្ណ)<br>-ប្រព័ន្ធផ្តល់សិទ្ធិការងារសម្រាប់កម្មករសំណង់ឆ្នាំ១៩៩៨<br>-ការទទួលខុសត្រូវរបស់និយោជក<br>-ការបញ្ចប់អាជ្ញាប័ណ្ណការងារ (Termination of Work permit)<br>-ការការពារការធ្វើទេសន្តរប្រវេសន៍ខុសច្បាប់<br>-ច្បាប់ការងាររបស់ពលករបរទេស ឆ្នាំ១៩៩១<br>-អាជ្ញាធរត្រួតពិនិត្យ និងការធ្វើអន្តោប្រវេសន៍ (Immigration and Checkpoints |

| | | | |
|---|---|---|---|
| | | | Authority) ធ្វើការយ៉ាងជិតស្និទ្ធិជាមួយនគបាល និងក្រសួងការងារ |
| អូស្ត្រាលី | -ច្បាប់ទេសន្តរប្រវេសន៍ឆ្នាំ១៩៥៨ និងបទប្បញ្ញត្តិនៃការធ្វើទេសន្តរប្រវេសន៍ ឆ្នាំ ១៩៩៤ ច្បាប់ទេសន្តប្រវេសន៍អូស្ត្រាលីឆ្នាំ ១៩៥៨ តាមរយៈការផ្តល់ទិដ្ឋការ[29]<br>-ច្បាប់គណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលីឆ្នាំ ១៩៨៦[30] | - «ទ្រឹស្តីសាជីវកម្មសម័យទំនើប» ផ្អែកទៅលក្ខណៈជាប្រពន្ធ័ដោយមានការចូលរួមនៃកម្លាំងពលកម្ម និងអាជីវកម្មយ៉ាងទូលំទូលាយ | - គម្រោងទីផ្សារការងារតម្រង់ទិសសម្រាប់ការជ្រើសរើសបុគ្គលិក<br>- កម្មវិធីទេសន្តរប្រវេសន៍របស់ប្រទេសអូស្ត្រាលី ៖ ការណែនាំដើម្បីធ្វើការផ្លាស់ប្តូរទិដ្ឋភាពដែលមិនធ្លាប់មាន [31]<br>- ១).នាយកដ្ឋានអន្តោប្រវេសន៍ និងការការពារព្រំដែន ២).កម្មវិធីមេរបស់រដ្ឋាភិបាលអូស្ត្រាលីដែលគ្រប់គ្រងដោយនាយកដ្ឋានសេវាធនធានមនុស្ស(Centrelink)៖ នេះជាភ្នាក់ងារដែលទូទាត់ការចំណាយលើសន្តិសុខសង្គម ៣). ការិយាល័យពន្ធដាររបស់ប្រទេសអូស្ត្រាលី ៤).នគបាលសហព័ន្ធអូស្ត្រាលី និង ៥).នគបាលរដ្ឋ។ |
| កាណាដា | -កត្តិកាសញ្ញារបស់ប្រទេសកាណាដានៃ សិទ្ធិ និងសេរីភាពនៅ ឆ្នាំ១៩៨២<br>-ស្តង់ដារច្បាប់ការងារ (Employment Standards Act) | - ទ្រឹស្តី «ធនធានមនុស្ស» ជាប្រព័ន្ធមួយរបស់ប្រទេសកាណាដា | - កំណត់គម្លាតនៃជំនាញដើម្បីបំពេញដោយការធ្វើអន្តោប្រវេសន៍ ឬកម្លាំងពលកម្មបរទេស<br>- កម្មវិធីពលករកសិកម្មតាមរដូវកាលនៅប្រទេសកាណាដា (Seasonal Agricultural Worker Program)[32] |

## បទពិសោធន៍ដែលអាចយកមកអនុវត្តបានរបស់ប្រទេសកាណាដា និងអូស្ត្រាលី

លើសពីនេះទៅទៀត គេបានផ្តល់ចំណាត់ថ្នាក់ឲ្យប្រទេសកាណាដាស្ថិតក្នុងចំណោមប្រទេសកំពូលទាំងដប់ ដោយសារការអនុវត្តន៍នូវល័ក្ខខ័ណ្ឌគោលនយោបាយល្អក្នុងការធ្វើសមាហរណកម្មទេសន្តរប្រវេសន៍ នៅក្នុងបរិបទសិទ្ធិមនុស្ស ការជ្រើសរើសយកប្រទេសណាមួយក៏ដោយក្នុងចំណោមប្រទេស កាណាដា ឬប្រទេសអូស្ត្រាលី នឹងផ្តល់សារៈប្រយោជន៍ដ៏សំខាន់ដល់ដំណើរទស្សនកិច្ចសិក្សារបស់ កម្ពុជា៖ វាជាបទពិសោធន៍គួឲ្យចាប់អារម្មណ៍ដែលសិក្សាពីក្របខ័ណ្ឌគតិយុត្តិរបស់ប្រទេសមួយ ហើយនឹងរបៀបនៃការគ្រប់គ្រង និងការធ្វើនិយ័តកម្មអន្តោប្រវេសន៍។ ប្រទេសទាំងនោះ ទទួលបានពិន្ទុខ្ពស់លើសន្ទស្សន៍គោលនយោបាយក្នុងការធ្វើសមាហរណកម្មទេសន្តប្រវេស៍ ទាក់ទងទៅនឹងការប្រឆាំងនៃការរើសអើង(តារាងទី២)។ ប្រទេសនីមួយៗ មានប្រវត្តិដ៏យូរអង្វែងនៃការធ្វើគោលនយោបាយទេសន្តរ-ប្រវេសន៍បើកចំហរដើម្បីទាក់ទាញជនបរទេសមកតាំងទីលំនៅ និងធ្វើការជាអចិន្ត្រៃនៅក្នុងប្រទេសរបស់ពួកគេ។ ក្រៅពីច្បាប់ទេសន្តរប្រវេសន៍របស់ពួកគេ ពួកគេទទួលបានជោគជ័យដ៏មានប្រសិទ្ធភាពក្នុងការគ្រប់គ្រងការធ្វើអន្តោប្រវេសន៍អន្តរជាតិ និងត្រួតពិនិត្យលើជនអន្តោប្រវេសន៍ខុសច្បាប់តាមរយៈប្រព័ន្ធរដ្ឋបាល ដែលបង្កើតឲ្យមានការផ្គត់ផ្គង់ និងតម្រូវការនៃការធ្វើអន្តោប្រវេសន៍។[27] នៅក្នុងបរិបទសិទ្ធិមនុស្ស ការត្រួតពិនិត្យ និងការគ្រប់គ្រងលើការធ្វើអន្តោប្រវេសន៍មានប្រសិទ្ធភាព និងតម្លាភាពបានលុះត្រាតែអនុវត្តតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលដំណើរការដោយអាជ្ញាធរចាត់តាំង(តារាងទី៣)។

## គោលនយោបាយ ឬប្រព័ន្ធបង្កើតឲ្យមានការផ្គត់ផ្គង់ (Supply-Driven Policy or System)

ទេសន្តរប្រវេសជនដែលមានសក្តានុពល ត្រូវបានលើកទឹកចិត្តឲ្យណែនាំខ្លួនឯងផ្ទាល់ដល់ប្រទេសដែលអនុវត្តលើដំណើរការត្រួតពិនិត្យ លើមូលដ្ឋានគ្រឹះនៃលក្ខណៈវិនិច្ឆ័យរបស់គោលបំណងមួយចំនួន។ បន្ទាប់មកប្រទេសដែលអនុវត្តផ្ទាល់ ជ្រើសរើសពលករបរទេសដែលមានសមត្ថភាពខ្ពស់បំផុតពីក្រុមជនអន្តោប្រវេសន៍ដែលមានសក្តានុពល។ ជនដែលធ្វើអន្តោប្រវេសន៍ដែលមានសក្តានុពលជាមួយនឹងពិន្ទុគ្រប់គ្រាន់តាមស្តង់ដា ដែលបានរៀបចំដោយប្រទេសនីមួយៗ បានជ្រើសរើសឲ្យធ្វើអន្តោប្រវេសន៍ និងផ្តល់សិទ្ធិឲ្យស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ។ ប្រព័ន្ធបង្កើតឲ្យមានការផ្គត់ផ្គង់ផ្តោតទៅលើការជ្រើសរើសជំនាញមូលដ្ឋានដោយមិនរាប់បញ្ចូលលកម្លាំងពលកម្មដែលមានជំនាញទាបពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។[27]

## ប្រព័ន្ធបង្កើតឲ្យមានតម្រូវការ (Demand-Driven System)

ប្រព័ន្ធបង្កើតឲ្យមានតម្រូវការ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីបំពេញនូវតម្រូវការបណ្ដោះអាសន្នរបស់កម្លាំងពលកម្មបរទេស។ ប្រព័ន្ធនេះត្រូវបានអនុវត្តដោយជោគជ័យនៅប្រទេសសិង្ហបុរីជាមួយនឹងការពង្រឹងតម្លាភាពនៃនីតិបញ្ញត្តិ និងឧបករណ៍គោលនយោបាយដែលមានស្រាប់(តារាងទី៤)។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងបង្កើតឲ្យមានតម្រូវការអន្តោប្រវេសន៍ គឺដើម្បបន្ធូរបន្ថយនូវវិសាលភាពមួយចំនួនដោយគម្រោងបង្កើតឲ្យមានការផ្គត់ផ្គង់កម្លាំងពលកម្មបរទេសបណ្ដោះអាសន្ន ដើម្បីបំពេញនូវតម្រូវការកម្លាំងពលកម្មរយៈពេលខ្លី តាមរយៈកម្មវិធីពលករបរទេសបណ្ដោះអាសន្នលើការស្នាក់នៅរយៈពេលខ្លីរបស់ពលករទេសន្តរប្រវេសន៍ដែលមានជំនាញទាប(កម្មករកសិដ្ឋាន និងការធ្វើអន្តោប្រវេសន៍នៅក្នុងប្រទេសដូចដែលកំពុងអនុវត្តនៅប្រទេសកាណាដា[31] និងប្រទេសអូស្ត្រាលី។[33])

គម្រោងបទប្បញ្ញត្តិទីផ្សារ នៃប្រព័ន្ធបង្កើតឲ្យមានតម្រូវការទាមទារឲ្យនិយោជកដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការទូទៅនៃការណែនាំពលករបរទេស ទាំងពលករដែលមានជំនាញ និងពលករដែលមិនមានជំនាញ ដើម្បីឲ្យរដ្ឋាភិបាលថ្នាក់មូលដ្ឋានអនុម័ត្ត។ សម្រាប់គោលបំណងនេះ និយោជកនៅប្រទេសកាណាដា ប្រើប្រាស់ភ្នាក់ងារជ្រើសរើសបុគ្គលិកដើម្បីជ្រើសរើលពលករស្របច្បាប់ពីបរទេស។[27, p.32]

ប្រទេសអូស្ត្រាលីអនុវត្តក្របខ័ណ្ឌនីតិប្បញ្ញាត្តិអន្តោប្រវេសន៍តាមរយៈកម្មវិធីទេសន្តរប្រវេសន៍របស់ពួកគេះអ្នកណែនាំទៅរកការផ្លាស់ប្ដូរទិដ្ឋភាពសម្រាប់ជួយដល់ជនអន្តោប្រវេសន៍ដែលមានគោលបំណងមករស់នៅ និងធ្វើការនៅប្រទេសអូស្ត្រាលី។ ចាប់តាំងពីឆ្នាំ១៩៤៥ នាយកដ្ឋានអន្តោប្រវេសន៍របស់ប្រទេសអូស្ត្រាលី បានទទួលជោគជ័យក្នុងការគ្រប់គ្រងជនអន្តោប្រវេសន៍ដែលមកដល់ និងតាំងទីលំនៅប្រហែលជា ៧,២ លាននាក់ ពីបណ្ដាប្រទេសនានា។[31] ជនអន្តោប្រវេសន៍ទាំងនោះ បានឆ្លងកាត់ដំណើរការជ្រើសរើស និងពាក្យសុំទិដ្ឋការ។ យោងទៅតាមលោក ចកអុឹម (Jocke M.) (២០១៥)៖

«... ច្បាប់ទេសន្តរប្រវេសន៍ ឆ្នាំ១៩៥៨ និងបទប្បញ្ញត្តិទេសន្តរប្រវេសន៍ឆ្នាំ១៩៩៤ កំណត់ការចូល និងវត្តមាន របស់ជនបរទេសនៅក្នុងប្រទេសអូស្ត្រាលី និងការចាកចេញរបស់ជនបរទេសពីប្រទេសអូស្ត្រាលី

---

ច្បាប់អន្តោប្រវេសន៍អូស្ត្រាលីមានភាពទូលំទូលាយ និងស្មុគស្មាញយ៉ាងខ្លាំង។ ក្របខ័ណ្ឌនីតិបញ្ញត្តិ និងនិយតកម្មមានច្រើនជាង ៣០០០ទំព័រ។ វាត្រូវបានកំណត់ដោយមេធាវីរបស់បទបញ្ញត្តិ និងអនុប្បញ្ញត្តិ។ មានប្រភេទទិដ្ឋាការចំនួន៩៧ និង ទិដ្ឋាការចំលងចំនួន ប្រាំបួនប្រភេទ [23]។

ហើយនឹងការនិរទេស(បណ្តេញ) ជនបរទេសចេញពីប្រទេសអូស្ត្រាលី និងជនមួយចំនួនផ្សេងទៀត»។ [31]

សរុបមក ឧបករណ៍គតិយុត្តិ និងកម្មវិធីអន្តោប្រវេសន៍នៅបណ្តាប្រទេសដែលបានលើកមកសិក្សាឡើងវិញនៅក្នុងការស្រាវជ្រាវនេះត្រូវបានគាំទ្រប្រកបដោយប្រសិទ្ធិភាព ដោយផែនការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមរយៈពេលវែង និងដំណើរការក្នុងការកំណត់គម្លាតជំនាញសម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ។ ឧទាហរណ៍ វិធីសាស្ត្រនេះអាចជួយឲ្យប្រទេសសិង្ហបុរីសម្រេចបាននូវគោលដៅជាតិថ្នាក់តំបន់ និងថ្នាក់សកលរូបនីកម្មរបស់ខ្លួន ដើម្បីគាំទ្រដល់តួនាទីជាមជ្ឈមណ្ឌលពាណិជ្ជកម្មរបស់ខ្លួននៅក្នុងតំបន់អាស៊ាន (ASEAN)។ ដំណើរការដើម្បីកំណត់តម្រូវការជនអន្តោប្រវេសន៍ដែលមានជំនាញក៏ត្រូវបានដួលដោយប្រទេសអភិវឌ្ឍន៍ល្អផ្សេងៗទៀតដូចជា ប្រទេសអូស្ត្រាលី និងប្រទេសកាណាដា ដើម្បីស្វាគមន៍ទេសន្តរប្រវេសជនអន្តរជាតិ មកស្នាក់នៅ និងធ្វើការជាអចិន្ត្រៃនៅក្នុងប្រទេសទាំងនោះ។បទប្បញ្ញត្តិ និងការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍ក្នុងប្រទេសទាំងនោះ បានគាំទ្រយ៉ាងមានប្រសិទ្ធិភាពដោយប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT)។

**ឧបសម្ព័ន្ធទី១៖ ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន អ្នកដែលចល័តទីលំនៅក្នុងស្រុក ជនមាតុភូមិនិវត្តន៍ (ជនភៀសខ្លួន និងអ្នកផ្លាស់ទីលំនៅ) ជនគ្មានសញ្ជាតិ និងការព្រួយបារម្ភផ្សេងៗទៀត របស់អង្គការសហប្រជាជាតិសិទ្ធិមនុស្ស (UNHCR) តាមប្រទេស/ទឹកដីនៃសិទ្ធិជ្រកកោនក្នុងឆ្នាំ២០១៥**

| | | កាណាដា | ស្វីស | អូស្ត្រាលី | កម្ពុជា | សិង្ហបុរី | ទូទាំងពិភពលោក |
|---|---|---|---|---|---|---|---|
| ជនភៀសខ្លួន | ជនភៀសខ្លួន | ១៣៥.៨៨៨ | ៧៣.៣៣៦ | ៣៦.៩១៧ | ៧៦ | | ៥.៤៨៣.៨៩៣ |
| | ប្រជាជនដែលស្ថិតក្នុងស្ថានភាពជាជនភៀសខ្លួន | - | - | - | - | | ៦៣៧.៥៣៤ |
| | ជនភៀសខ្លួនសរុប និងប្រជាជនដែលស្ថិតក្នុងស្ថានភាពជាជនភៀសខ្លួន | ១៣៥.៨៨៨ | ៧៣.៣៣៦ | ៣៦.៩១៧ | ៧៦ | | ១៦.១២១.៤២៧ |
| | អ្នកត្រូវបានជួយដោយអង្គការសហប្រជាជាតិសិទ្ធិមនុស្ស | - | - | - | ៧១ | | ១២.២៨២.៧៩២ |
| | អ្នកស្វែងរកសិទ្ធិជ្រកកោន (ករណីមិនទាន់បានដោះស្រាយ) | ១៩.៦៤២ | ៣២.៧០១ | ២០.៦៧៧ | ២៧ | | ៣.២១៩.៩៤១ |
| | ការវិលត្រឡប់របស់ជនភៀសខ្លួន | - | - | - | ១ | | ២០១.៤១៥ |
| | ជនដែលផ្លាស់ទីលំនៅក្នុងស្រុកត្រូវបានការពារ/ជួយដោយអង្គការសហប្រជាជាតិសិទ្ធិមនុស្សរួមទាំងប្រជាជនដែលស្ថិតក្នុងស្ថានភាពផ្លាស់ប្តូរទីលំនៅផងដែរ | - | - | - | - | | ៣៧.៤៩៤.១៧២ |
| | ការវិលត្រឡប់មកវិញរបស់ជនដែលផ្លាស់ទីលំនៅ | - | - | - | - | | ២.៣១៧.៣១៤ |
| | និបេតិកជន(អ្នកគ្មានសិទ្ធិក្លាយជាប្រជាពលរដ្ឋ)ដែលស្ថិតនៅក្រោម អណត្តិរបស់អង្គការសហប្រជាជាតិសិទ្ធិមនុស្ស | - | ៦៩ | - | - | | ៣.៦៨៧.៧២៩ |
| | ការព្រួយបារម្ភផ្សេងរបស់អង្គការសហហប្រជាជាតិសិទ្ធិមនុស្ស | - | - | - | ១៩៧ | ១ | ៨៧០.៧៤០ |
| | ការព្រួយបាម្ភរបស់ប្រជាជនសរុប | ១៥៥.៥៣ | ១០៦.១០៦ | ៥៧.៥៩៤ | ៣០ | ១ | ៦៣.៩១២.៧៣៨ |

ប្រភព៖ អង្គការសហប្រជាជាតិសិទ្ធិមនុស្ស (២០១៥) និន្នាការសកល៖ ការចល័តទីលំនៅដោយបង្ខំ នៅឆ្នាំ ២០១៥

**ឧបសម្ព័ន្ធទី២៖ សន្ទស្សន៍គោលនយោបាយសមាហរណកម្មទេសន្តរប្រវេសន៍ឆ្នាំ២០១៤** (Migration Integration Policy Index) ( **ពិន្ទុ** )[15]

| | **អូស្ត្រាលី** | **កាណាដា** | **ស្វីស** |
|---|---|---|---|
| ពិន្ទុមធ្យមសរុបរបស់សន្ទស្សគោលនយោបាយសមាហរណកម្មទេសន្តរប្រវេសន៍ | ៦៦ | ៦៨ | ៤៩ |
| *១. **ទីផ្សារការងារចល័ត៖** សមាហរកម្មទីផ្សារពលកម្មកើតមានឡើងគ្រប់ពេល និងផ្អែកតាមគោលនយោបាយទូទៅ បរិបទ ជំនាញរបស់ជនអន្តោប្រវេសន៍ និងមូលហេតុនៃការធ្វើទេសន្តរប្រវេសន៍។ គោលនយោបាយការងារដែលមានប្រសិទ្ធភាពមួយចំនួនអាចជាថ្មី និងតូចពេក ដើម្បីឈានទៅដល់ប្រជាជនដែលមិនមែនជាសមាជិកសហភាពអ៊ឺរ៉ុប មានតម្រូវការរបស់បុរស និងស្ត្រី ដែលកម្រនឹងទទួលបានវគ្គបណ្តុះបណ្តាល និងផលប្រយោជន៍។* | ៥៨ | ៨១ | ៥៩ |
| *២. **ជួបជុំគ្រួសារ៖** ចំពោះគ្រួសារឆ្លងដែនដែលមានសមាជិកតិច គោលនយោបាយជួបជុំគ្រួសារ ជាកត្តាដ៏សំខាន់មួយដែលអាចកំណត់បានថាតើពួកគេអាចជួបជុំគ្នាវិញនៅក្នុងប្រទេសបានដែរ ឬទេ។* | ៦៧ | ៧៩ | ៤៨ |
| *៣. **ការអប់រំ៖** បណ្តាប្រទេសដែលទទួលបានជនធ្វើអន្តោប្រវេសន៍ច្រើន និងលទ្ធផលមិនល្អរបស់សិស្សអន្តោប្រវេសន៍ ជាមួយនឹងអ្វីដែលថ្មីៗជាច្រើន ប៉ុន្តែនៅទន់ខ្សោយនៅឡើយ បានកំណត់គោលដៅគោលនយោបាយអប់រំ ដែលជានិច្ចកាលអនុវត្តមិនបានល្អ ឬក៏មិនមានប្រសិទ្ធភាព។* | ៧៦ | ៦៥ | ៤២ |
| *៤. **សុខាភិបាល៖** ភាពខុសគ្នាមួយចំនួនធំ កើតមានឡើងចំពោះទំហំនៃការទទួលបានសេវាថែទាំសុខភាព និងសមត្ថភាពក្នុងការទទួលបានសេវាថែទាំសុខភាពរបស់ជនអន្តោប្រវេសន៍រវាងប្រទេស និងប្រទេស។ គោលនយោបាយតែងតែទទួលបរាជ័យនៅពេលដែលលើកយកតម្រូវការថែទាំសុខភាពជាក់លាក់របស់ពួកគេមកពិចារណា។* | ៦៧ | ៤៩ | ៧០ |
| *៦. **ការចូលរួមក្នុងឆាកនយោបាយ៖** ការលើកកម្ពស់ការចូលរួមរបស់ជនអន្តោប្រវេសន៍* | ៦៤ | ៤៨ | ៥៨ |

| | | | |
|---|---|---|---|
| *ក្នុងឆាកនយោបាយ គឺជាសញ្ញាប្រទេសដែលមានទំនុកចិត្ត ទៅលើការធ្វើអន្តោប្រវេសន៍។ គោលនយោបាយរឹតបន្តឹងលុបបំបាត់សិទ្ធិប្រជាពលរដ្ឋដែលមិនមែនជាសមាជិកសហភាពអឺរ៉ុបចំនួន១០លាននាក់ ចេញពីការបោះឆ្នោត និងការចូលរួមក្នុងសកម្មភាពមួយចំនួនតាមរយៈអង្គភាពពិគ្រោះយោបល់ទន់ខ្សោយ និងថវិកាសម្រាប់អង្គការអន្តោប្រវេសន៍។* | | | |
| ***៧. លំនៅដ្ឋានអចិន្ត្រៃ៖*** *សុវត្ថិភាពរបស់អ្នកមកតាំងទីលំនៅអចិន្ត្រៃជាជំហ៊ានមូលដ្ឋានដែលអាចឈានទៅដល់ការទទួលបានសិទ្ធិជាប្រជាពលរដ្ឋស្របច្បាប់ និងលទ្ធផលសមាហរណកម្មប្រសើរជាងមុន។ ជនអន្តោប្រវេសន៍ភាគច្រើនមានសិទ្ធិគ្រប់គ្រាន់ក្នុងការតាំងទីលំនៅ និងមុខវិជ្ជាសំខាន់ៗភាគច្រើនមានគោលដៅថ្មី និងយូរអង្វែងមកហើយ។* | *៥៤* | *៦២* | *៥១* |
| ***៨.ទទួលបានសញ្ជាតិ៖*** *តម្រូវការជាច្រើនលើការធ្វើកំណែទម្រង់ប្រជាពលរដ្ឋ អាចបង្កើនអត្រាចូលសញ្ជាតិគួឲ្យកត់សម្គាល់ និងបង្កើនលទ្ធផលនៃការធ្វើសមាហរណកម្មផ្សេងៗទៀតសម្រាប់ប្រជាពលរដ្ឋដែលមានសក្តានុពលជាច្រើន។* | *៦៩* | *៦៧* | *៣១* |
| ***៩. ប្រឆាំងនឹងការរើសអើង៖*** *ដំបូងបានធ្វើកំណែទម្រង់ ហើយពេលនេះជាពេលធ្វើការអនុវត្ត។ ច្បាប់ថ្មី និងគោលនយោបាយទន់ជ្រាយ មានន័យថាជនរងគ្រោះ ដែលមានសក្តានុពលទទួលបានដំណឹង និងការគាំទ្រតិចតួចបំផុត សូម្បីតែជំហ៊ានដំបូងក្នុងការទទួលបានយុត្តិធម៌ដ៏យូរអង្វែង ដោយសារតែប្រជាជនភាគច្រើនជួបប្រទះនឹងការរើសអើងមិនបានរាយការណ៍ដល់អាជ្ញាធរ។* | *៧៤* | *៩២* | *៣១* |

# ឯកសារយោង


1. (2008). Immigration. *Cambridge Advance Learners Dictionary 3rd Edition*
2. Tim, F. (2016). *Cambodia's Anti-Vietnam Obsession* [Online]. The Diplomat. Available: http://thediplomat.com/2016/09/cambodias-anti-vietnam-obsession/ [Accessed May 5 2017].
3. UNDP. (2016). *Human Development Report 2016: Human Development for Everyone* [Online]. Available: http://hdr.undp.org/sites/default/files/2016_human_development_report.pdf [Accessed May 10 2017].
4. United Nations. (2015). *International Migration Report 2015* [Online]. Available: http://www.un.org/en/development/desa/population/migration/publications/migrationreport/docs/MigrationReport2015_Highlights.pdf.
5. United Nations. (2015). *Trends in International Migrant Stock: Migrants by Destination and Origin* [Online]. Department of Economic and Social Affairs, Population Division Available: http://www.un.org/en/development/desa/population/migration/data/estimates2/estimates15.shtml [Accessed May 11 2017].
6. Admin. (2016). *Over 200 illegal immigrants harbourers in Singapore are foreigners* [Online]. States Times Review. Available: http://statestimesreview.com/2016/02/19/over-200-illegal-immigrants-harbourers-in-singapore-are-foreigners [Accessed May 15 2017].
7. Yeoh, B. S. & Lam, T. (2016). Immigration and Its (Dis) Contents: The Challenges of Highly Skilled Migration in Globalizing Singapore. *American Behavioral Scientist,* 60**,** 637-658.
8. Mizanur, R. (2017). *Bangladeshi Migration to Singapore.* [Online]. Available: http://www.springer.com/cda/content/document/cda_downloaddocument/9789811038563-c2.pdf?SGWID=0-0-45-1602560-p180645441 [Accessed May 15 2017].
9. Wright, C., Clibborn, S., Piper, N. & Cini, N. (2016). *Economic migration and Australia in the 21st century* [Online]. Available: https://www.lowyinstitute.org/publications/economic-migration-and-australia-21st-century [Accessed May 3 2017].
10. Wilkinson, L. & Garce, J. (2017). *The Economic Integration of Refugees in Canada: A Mixed Record* [Online]. Available: http://www.migrationpolicy.org/research/economic-integration-refugees-canada-mixed-record [Accessed May 4 2017].
11. ManpowerGroup Inc (2015). *Telent Shortage Survey Report* [Online]. Available: http://www.manpowergroup.com/wps/wcm/connect/db23c560-08b6-485f-9bf6-f5f38a43c76a/2015_Talent_Shortage_Survey_US-lo_res.pdf?MOD=AJPERES [Accessed May 5 2017].
12. Sarr, H. (2017). *Stradling Two Worlds: Highly Skilled Migrants from Senegambia and Switzerland* [Online]. Migration Policy Institute. Available: http://www.migrationpolicy.org/article/straddling-two-worlds-highly-skilled-migrants-senegambia-and-switzerland [Accessed May 8 2017].

13. Sarr, K. (2016). *Highly skilled migrants in Senegambia and Switzerland*, UNINOVA.
14. Schmid, P. (2016). *Highly skilled migrants in Senegambia and Switzerland* [Online]. Unversity of Basel. Available: https://www.unibas.ch/en/Research/Uni-Nova/Uni-Nova-128/Uni-Nova-128-Highly-skilled-migrants-in-Senegambia-and-Switzerland.html [Accessed May 8 2017].
15. United Nations. (2015). *Integrating migration into the 2030 Agenda for Sustainable Development* [Online]. Available: http://www.un.org/en/development/desa/population/migration/publications/populationfacts/docs/MigrationPopFacts20155.pdf [Accessed May 8 2017].
16. UN-HABiTAT. (2014). *Forced Eviction* [Online]. United Nations. Available: http://www.ohchr.org/Documents/Publications/FS25.Rev.1.pdf [Accessed May 9 2017].
17. UNHCR. (2015). *Global Trends: Forced Displacement in 2015* [Online]. Available: http://www.unhcr.org/576408cd7.pdf [Accessed May 16 2017].
18. The Centre on Housing Rights and Evictions. (2008). *Successes and Strategies: Responses to Forced Evictions* [Online]. Available: http://abahlali.org/files/averting%20evictions.pdf [Accessed May 20 2017].
19. Centre on Housing Rights and Evictions (COHRE). (2012). *Forced Evictions: Violations of Human Rights - Global Survey* [Online]. Available: http://www.ucl.ac.uk/dpu-projects/drivers_urb_change/urb_society/pdf_violence_rights/COHRE_global_survey_forced_evictions.pdf [Accessed May 20 2017].
20. NESW Government. (2016). *Stolen Generations: Victims to get $73 million compensation* [Online]. Available: http://www.abc.net.au/news/2016-12-02/stolen-generations-to-get-$73-million-compensation-package-nsw/8086126 [Accessed May 21 2017].
21. United Nations. (22 July 2009). *Call for Government to protect against forced eviction in Port Moresby* [Online]. Available: http://pacific.ohchr.org/docs/PR_PNG_220709.doc. [Accessed May 9 2017].
22. ILO. *SDC Migration Network – Global Meeting on Migration and Development. Migration and Development in the 2030 Agenda: From Global Commitment to Collective Action* [Online]. Available: http://mdglobalmeeting2016.org/wp-content/uploads/2016/05/Global-Meeting-2016-ILO-Discussion-Note-on-Decent-Work-and-Migration.pdf [Accessed May 22 2017].
23. Huddleston, T. & Sánchez Montijano, E. (2015). *Integration Policies: Who Benefits? Policy brief* [Online]. Available: http://mipex.eu/sites/default/files/downloads/files/mipex_integration-policy_policy-brief.pdf. [Accessed May 10 2017].
24. Migration Policy Group. (2015). *Migrant Integration Policy Index 2015* [Online]. Barcelona Center for International Affairs. Available: http://www.mipex.eu/sites/default/files/downloads/pdf/mipex_GENERAL_PRESENTATION.pdf [Accessed May 8 2017].
25. Universityof Fribourg. (2016). *The Regulation of the Immigration of the Low Skilled and Unskilled Labor Force in Switzerland and in the EU* [Online]. Available: http://nccr-onthemove.ch/wp_live14/wp-content/uploads/2016/07/160622_WorkshopReport_Final.pdf [Accessed May 8 2017].

26. Epilog, A. (2016). *The Regulation of the Immigration of the Low Skilled and Unskilled Labor Force in Switzerland and in the EU* [Online]. Available: http://nccr-onthemove.ch/knowledge-transfer/dialogue-2/academic-workshops/the-regulation-of-the-immigration-of-the-low-skilled-and-unskilled-labor-force-in-switzerland-and-in-the-eu/ [Accessed May 10 2017].
27. Rahman, M. M. (2017). *Immigration and Integration Policy in Singapore* [Online]. Springer Nature Singapore Pte Ltd. Available: http://www.springer.com/gp/book/9789811038563. .
28. Chowdhry, M. (2013). *Controlling Immigrants: An Asian Perspective* [Online]. The In-House Lawyer. Available: http://www.inhouselawyer.co.uk/index.php/legal-briefing/controlling-immigration-an-asian-perspective/ [Accessed May 15 2017].
29. Vongchan, R., Bor, H., Chhan, P. & Chy, T. (2016). Immigration Laws of Australia and Cambodia, and Role of Parliaments on Immigration. Phnom Penh: Parliamentary Institute of Cambodia.
30. Australian Government. (1986). *Australian Human Rights Commission Act 1986* [Online]. Available: https://www.legislation.gov.au/Details/C2017C00143 [Accessed May 20 2017].
31. Jockel, M. (2015 ). *Australia's Migration Programme: A Guide to an Ever-Changing Landscape* [Online]. Available: http://whoswholegal.com/news/features/article/32284/australias-migration-programme-guide-ever-changing-landscape [Accessed May 20 2017].
32. Government of Canada. (2016). *Agricultural workers – Work temporarily in Canada* [Online]. Canada: Government of Canada. Available: http://www.cic.gc.ca/english/work/permit-agriculture.asp [Accessed May 20 2017].
33. Parliament of Australia. (2013). *Inquiry into Migration and Multiculturalism in Australia* [Online]. House of Representatives Committees. Available: http://www.aph.gov.au/parliamentary_business/committees/house_of_representatives_committees?url=mig/multiculturalism/report.htm. [Accessed May 20 2017].